# ខ្លឹមសារជំនឿលើព្រះយេស៊ូវគ្រីស្ទ

# ក្នុង៦មេរៀន

## មេរៀនទី១ តើព្រះគម្ពីរព្រះយេស៊ូវជាអ្វី ហើយមកពីណា?

**លំនាំដើម**

ខ្ញុំជាគ្រូបង្រៀនព្រះគម្ពីរព្រះយេស៊ូវ ជាអ្នកផ្សាយសាសនា ឬសាសនទូត។ តាមពិតទៅពាក្យ

«អ្នកផ្សាយសាសនា» និង «សាសនាទូត» ក៏ពាក្យមិនត្រឹមត្រូវទេ ពីព្រោះខ្ញុំមិនមកក្នុងឈ្មោះសាសនាទេ ខ្ញុំមកក្នុងព្រះនាមរបស់ព្រះយេស៊ូវវិញ។ ខ្ញុំមកក្នុងឈ្មោះថា ជាទូតរបស់ព្រះយេស៊ូវគ្រីស្ទ។ ព្រះគម្ពីរថា

**«យើងជាទូតរបស់ព្រះគ្រីស្ទ» ២កូរិនថូស ៥:២០**

ដូច្នេះ ព្រះយេស៊ូវ ដ៏ជាព្រះអម្ចាស់របស់ខ្ញុំ ទ្រង់មានបន្ទូលទៅកាន់អ្នក តាមរយៈខ្ញុំ។ ព្រះគម្ពីរនេះ គឺព្រះគម្ពីរបរិសុទ្ធ ជាព្រះបន្ទូល ជាសំលេងរបស់ព្រះទៅកាន់មនុស្សលោក ហើយខ្ញុំជាគ្រូដែលអធិប្បាយតែតាមព្រះគម្ពីរនេះ។ គំនិតរបស់ខ្ញុំ ប្រាជ្ញារបស់ខ្ញុំមិនសំខាន់ទេ សំខាន់គឺតែព្រះបន្ទូលរបស់ព្រះ។

ស្ថានទូតជាតំណាងសម្រាប់ប្រទេសរបស់ខ្លួនប៉ុណ្ណោះ។

អ្នកជឿលឿព្រះយេស៊ូវទាំងអស់ដែលនាំគេស្គាល់ព្រះតាមរយៈព្រះគម្ពីរជាទូតរបស់ព្រះគ្រីស្ទដែរ។

ព្រះគម្ពីរអានថា

**«យើងជាទូតរបស់ព្រះគ្រីស្ទ ហាក់ដូចជាព្រះកំពុងអង្វរតាមរយៈយើង គឺយើងអង្វរអ្នករាល់គ្នាជំនួសព្រះគ្រីស្ទថា ចូរជានានឹងព្រះវិញទៅ។» ២កូរិនថូស ៥:២០**

មួយទៀត ព្រះអម្ចាស់កំពុងអង្វរតាមរយៈព្រះគម្ពីរ នឹងសំលេងរបស់ខ្ញុំថា «ចូរជានានឹងព្រះ»។ តើព្រះមួយណាដែលយើងត្រូវជានា?

សូមឲ្យបងប្អូនស្តាប់ឃ្លាទីមួយក្នុងព្រះគម្ពីរ *(បង្ហាញព្រះគម្ពីរជាភាសាខ្មែរ)*

**«កាលដើមដំបូងឡើយ ព្រះបានបង្កើតផ្ទៃមេឃ និងផែនដី» លោកុប្បត្តិ ១:១**

ព្រះដែលយើងត្រូវស្គាល់ ព្រះដែលយើងត្រូវជានានឹងនោះ គឺព្រះដែលបានបង្កើតផ្ទៃមេឃ និងផែនដី ជាព្រះអាទិករ ព្រះអាទិទេព**ដ៏ពិត**។

ហើយមួយទៀត តើយើងត្រូវជានាជាមួយព្រះអង្គនោះយ៉ាងម៉េចកើត? ក្នុង៦មេរៀនដែលយើងនឹងរៀនជាមួយគ្នានេះ យើងនឹងឃើញចម្លើយរបស់សំណួរសំខាន់នេះ។

## ប្រភពនៃព្រះគម្ពីរ

លោកព្យាការី ឬលោកហោរា បានសរសេរកត់ទុកព្រះបន្ទូលរបស់ព្រះ។ មានលោកប្រហែលជា៤៤អ្នកដែលបានកត់ទុកព្រះបន្ទូលព្រះ ដែលយើងហៅរាល់ថ្ងៃនេះថា «ព្រះគម្ពីរ»។ លោកទាំងអស់នោះ ជាសាសន៏ហេប្រឺ ជាសាសន៏អ៊ីស្រអែល លើកលែងតែម្នាក់ជាសាសន៏ក្រិក។ ដូច្នេះ លោកដែលបានសរសេរព្រះគម្ពីរជិតទាំងអស់គ្នាមកពីទ្វីបអាស៊ីខាងលិច ហើយគម្ពីរដើមបាន សរសេរមកជាភាសាហេប្រឺ នឹងភាសាក្រិក។

(*មិនមែនជាភាសារបារាំង ឬអង់គ្លេសទេ បង្ហាញសិស្សព្រះគម្ពីរជាភាសាខ្មែរ*)

**«ដោយដឹងសេចក្តីនេះជាមុនដំបូងថា គ្មានពាក្យទំនាយណាក្នុងគម្ពីរ ដែលបកស្រាយបានតាមតែគំនិតរបស់មនុស្សឡើយ ដ្បិតសេចក្តីទំនាយមិនដែលចេញមកពីបំណងរបស់មនុស្សទេ គឺមនុស្សថ្លែងព្រះបន្ទូលរបស់ព្រះ តាមដែលព្រះវិញ្ញាណបរិសុទ្ធបណ្តាល។» ២ ពេត្រុស ២:២០-២១**

ខគម្ពីរនេះបញ្ជាក់ថា លោកព្យាការីដែលកត់ទុកព្រះគម្ពីរបរិសុទ្ធ មិនបានសរសេរតាមគំនិត ឬប្រាជ្ញាខ្លួនលោកនោះទេ គឺព្រះវិញ្ញាណរបស់ព្រះដែលបណ្តាលលោកវិញ។

ព្យាការីទាំងនេះ រស់នៅសម័យជាមួយគ្នាខ្លះ តែជិតទាំងអស់មិនដែលស្គាល់គ្នាផង។ ក្នុងចំណោមព្យាការីនោះ មានស្តេក គ្រូពេទ្យ អ្នកទាពុន្ធ មន្ត្រី អ្នកគ្វាលចៀម អ្នកនិសាតត្រី ហើយគ្រូបណ្ឌឹតសាសនា។

## អាយុនៃព្រះគម្ពីរបរិសុទ្ធ

មានលោកព្យាការីរបស់ព្រះចាប់ទាំងពីសម័យដើមរបស់ផែនដីនេះមក តែលោកព្យាការីដែលកត់ទុកគម្ពីរមុនគេបង្អស់គឺ លោកម៉ូសេ **១៥០០ឆ្នាំមុនព្រះគ្រិស្តសករាជ**។ លោកដែលកត់ទុកគម្ពីរក្រោយគេបង្អស់គឺ លោកយ៉ូហាន ជាសវ័ករបស់ព្រះយេស៊ូវ ប្រហែល **១០០ឆ្នាំក្រោយព្រះគ្រិស្តសករាជ**។

ព្រះគម្ពីរបរិសុទ្ធមានពីរផ្នែក ផ្នែកទីមួយជាព្រះគម្ពីរទាំងអស់ដែលមានកត់ទុកមុនព្រះគ្រិស្តសករាជ ហើយផ្នែកទីពីរ គឺព្រះគម្ពីរដែលមានកត់ទុកក្រោយព្រះគ្រិស្តសករាជ។

(*បង្ហាញសិស្សថា ព្រះគម្ពីរក្រាស់ ហើយគម្ពីរសញ្ញាចាស់មានច្រើន*)

ដូច្នេះមានជំនឿទៅលើព្រះន័យយើងខ្ញុំតាំងពីសម័យដើមមក។ ជំនឿជឿលើព្រះយេស៊ូវជាការបន្តពីសាសនា ជំនឿដើមរបស់មនុស្សលោក។

ព្រះគម្ពីរជាការពិតសុទ្ធ ;

**«គ្រប់ទាំងបទគម្ពីរ ព្រះទ្រង់បានបញ្ចេញព្រះវិញ្ញាណបណ្តាលឲ្យតែង» ២ធីម៉ូថេ ៣:១៦**

មានសំណួរខ្លះដែលយើងគួរយកចិត្តទុកដាក់ គឺបើមានគម្ពីរច្រើនមុនព្រះគ្រិស្តសករាជអញ្ចើង តើព្រះយេស៊ូវត្រូវជាអ្នកណា? បើសិនមានជំនឿទៅលើព្រះន័យយើងខ្ញុំ តាំងពីសម័យដើមមកនេះមែន តើព្រះយេស៊ូវជាអ្នកណាទៅវិញ? ចំលើយសម្រាប់សំណួរទាំងពីរនេះមានក្នុងមេរៀនក្រោយ។

គ្មានអ្វីៗផ្សេងទៀត ដែលសំខាន់ជាជៀងព្រះគម្ពីរនេះ សូមឲ្យបងប្អូនទាំងអស់គ្នាមានការយកចិត្តទុកដាក់ទៅលើមេរៀនទាំងនេះ យើងត្រូវស្គាល់ព្រះដើម្បីបានជីវិតដ៏ពិត។

(*ចែកខគម្ពី យ៉ូហាន ៣:១៦ ឲ្យសិស្ស ដើម្បីពិចារណាមុនជួបគ្នារៀនមេរៀមទី២*)